# នមោរតន

# កថា

## “សម្ដែងរឿងនមោនិងរតនត្រ័យ”

ការរៀបរៀងរបស់

ព្រះមហា ឡាយ សាមរ

វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ការផ្សាយរបស់

សុវណ្ណភូមិ វ.វ. ភ្នំពេញ

បោះពុម្ព

ព.ស.២៤៩៤ គ.ស.១៩៥១

# បុព្វកថា

បណ្តាមនុស្សទាំងឡាយ ក្នុងពិភពលោកទាំងស្រុងតែងមានការជឿជាធំ ជាប្រធាន ជាច្បង ជាកម្លាំង ជាគ្រូ ជាចំណុចរបស់ចិត្តជាដើម រួមសេចក្តីយ៉ាងខ្លីមក ក៏គឺសទ្ធានេះឯង, កាលបើមនុស្សទាំងឡាយមានសទ្ធាមកប្រតិស្ឋាននៅក្នុងមត្ថលុង្គ (ខួរក្បាល) ដូច្នេះហើយ ចំណែកសេចក្តីជ្រះថ្លាស្រឡាញ់ជិតដិតស្និទ្ធស្នាល ធ្វើសក្ការៈគោរពបូជាគ្រប់បែបយ៉ាង ក៏កើតឡើងជាលំដាប់ដោយតាមក្រោយជាហូរហែមក។

តែមនុស្សទាំងឡាយនោះ កាលបើមានសទ្ធា គឺសេចក្តីជឿនិងបសាទៈ សេចក្តីជ្រះថ្លា មកដក់ត្រាំនៅក្នុងខួរក្បាលវេលាណា ក៏តែងតែមានវត្ថុបំណង២យ៉ាង។

ចុះវត្ថុបំណង២យ៉ាងគឺអ្វីខ្លះ?

ឆ្លើយថា វត្ថុបំណង២យ៉ាងនោះគឺៈ

១-ចង់សម្តែងខ្លួនឱ្យប្រាកដដើម្បីឱ្យអ្នកទាំងពួងគេដឹងគេឮថា ខ្លួនជាអ្នកមានសេចក្តីជឿទៅលើវត្ថុឬសរណៈនោះៗ។

២-ចង់សម្តែងខ្លួនឱ្យប្រាកដជាក់ដល់សរណវត្ថុដែលខ្លួនជឿនោះ ដើម្បីនឹងបានស្គាល់ជាក់លាក់នូវសរណវត្ថុនោះ ហើយនឹងឱ្យសរណវត្ថុនោះ ជួយមើលសុខទុក្ខរបស់ខ្លួនវិញផង។

ព្រោះហេតុនោះ ដើម្បីសម្តែងសទ្ធានិងបសាទៈឱ្យប្រាកដ ដែលគោរពរាប់អានសាសនាព្រះពុទ្ធក្តី សាសនាព្រាហ្មណ៍ក្តី សាសនាខ្មោចដែលក្លាយចេញពីសាសនាព្រាហ្មណ៍ជាដើមក្តី គេតែងមានវិធីសូត្រធម៌ថ្វាយបង្គំចំពោះសាសនានោះៗ ដែលគេហៅថា នមស្ការ ដូចសាសនាខ្លះៗ ក្រៅពីពុទ្ធសាសនា មានបទនមស្ការរបស់គេថា ឱម សិទ្ធី ស្វាហៈ ជាដើម។

តែចំណែកព្រះពុទ្ធសាសនា ដែលយើងជាតិកម្ពុជាទាំងឡាយធ្លាប់កាន់ជឿតាមជាយូរយារច្រើនយុគនិងសតវត្សរ៍មកហើយនោះ ក៏គង់មានបទនមស្ការមួយដោយឡែកដែរ។

ហេតុនេះ ក្នុងដំណើរនេះ យើងខ្ញុំនឹងអធិប្បាយពន្យល់ត្រង់បទនមស្ការនៃអ្នកកាន់ពុទ្ធសាសនា ដូចយើងធ្លាប់សូត្រធ្លាប់ថារួចមកហើយថា នមោ។ល។ ដោយសេចក្តីជាសង្ខិតន័យដូចតទៅនេះ ÷

ពាក្យថា "នមោ" នេះ គឺជាបទនមស្ការមួយដែលមាំផង ខ្លាំងពូកែស័ក្តិសិទ្ធិផងប្រសើរវិសេសផង សម្រាប់អ្នកដែលកាន់ព្រះពុទ្ធសាសនាគ្រប់ជាតិគ្រប់ភាសាទាំងអស់ សឹងដែលមានមកក្នុងគម្ពីរបាលីជាច្រើនកន្លែង ដូចជាមានក្នុងសូត្រផ្សេងៗមានគម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈនិងគម្ពីរទីឃនិកាយ បាដិកវគ្គ ដែលព្រះគន្ថរចនាចារ្យទាំងឡាយលោកបានដោតក្រងទុកតាមដំណើរសេចក្តី ដែលលោកសម្តែងទុកថា ពាក្យថានមោនេះ ជាឧទានវាចា មិនមែនជាពាក្យនមស្ការដែលគេធ្លាប់សូត្រគ្រប់ព្រឹកគ្រប់ល្ងាចដូចសព្វថ្ងៃនេះទេ។

តាមសេចក្តីពិត ពាក្យថាឧទានៗនេះ លោកប្រែថាពាក្យសម្រាប់បន្លឺឡើងបានដល់វាចាដែលលាន់ឮចេញមកដោយអំណាចនៃសេចក្តីរីករាយក្នុងចិត្ត ចម្លែកអស្ចារ្យក្នុងចិត្តនិងសេចក្តីជ្រះថ្លាផូរផង់នៃចិត្តឬដោយការដែលមានសម្បជញ្ញា គឺសេចក្តីដឹងខ្លួន, ដោយពេញកម្លាំងឥតទើសទាក់ចំពោះព្រឹត្តិការណ៍នោះៗ យើងគួរសន្និដ្ឋានបានថា ពាក្យថានមោបទនេះ ទុកដូចជាវត្ថុដែលមានតម្លៃថ្លៃថ្នូរគួរគប្បីរក្សាទុកនិងគួរនាំយកទៅបញ្ចេញសម្តែងឱ្យសមតាមកាលៈទេសៈ មិនមែនសម្រាប់ប្រើជាអចិន្ត្រៃយ៍ដូចជាវត្ថុធម្មតាទេ តែពេលក្រោយតមក ក៏នមោនេះបានប្រែក្លាយ

ទៅជាធមិមួយយ៉ាងសំខាន់បំផុត គឺវេលាធ្វើបុណ្យពិធីអ្វីនីមួយម្ដងៗ គេតែងយកនមោនេះទៅតាំងធ្វើជាប្រធានគ្រប់ពិធីទួទៅទាំងអស់ បានជាយកប្រើដូច្នោះនោះ ក៏ព្រោះនមោនេះជាបទនមស្ការ ដែលសម្ដែងសេចក្ដីគោរពឱនលំទោនចំពោះព្រះរតនត្រ័យ ដោយអាស្រ័យបសាទៈ គឺសេចក្ដីជ្រះថ្លារបស់អ្នកដែលពោលបន្លឺឡើងដែលគេរាប់អានថា ទុកជាធមិនមស្ការ ដែលសមរម្យតាមទំនងរបស់កិច្ចការនិងគ្រប់កាលគ្រប់វេលារបស់អ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់។

ព្រោះហេតុនោះ យើងខ្ញុំនឹងសម្ដែងក្នុងដំណើររឿងនមោនេះ ដើម្បីជាដំណើរសម្រាប់បណ្ដុះបណ្ដាលនូវសទ្ធានិងបសាទៈរបស់លោកអ្នកត្រូវការចង់ជ្រាប ក្នុងដំណើរនៃរឿងនមោនេះ យើងខ្ញុំមានសេចក្ដីសង្ឃឹមទុកជាមុនថា នមោកថា នេះគង់បានទៅជាប្រកាន់ដៃរបស់លោកអ្នកមានសេចក្ដីត្រូវការចង់ចេះក្នុងរឿងនេះ បើមិនច្រើនក៏តិច ហេតុនេះ បើមានឃ្លៀងឃ្លាតឬខុសបាត់ មិនសមរម្យត្រង់ឯណានីមួយ សូមអភ័យទោសអំពីសម្នាក់អ្នកអាននិងអ្នកស្ដាប់ដោយមេត្រីភាព!

# សម្តែងអំពីបទ នមោ

ពាក្យថា “នមោ” នេះ គឺជាពាក្យសម្រាប់នមស្ការមួយយ៉ាងសំខាន់បំផុតរបស់អ្នកកាន់ព្រះពុទ្ធសាសនា ព្រោះពួកពុទ្ធបរិស័ទទាំងឡាយ វេលាដែលផ្តួចផ្តើមធ្វើការកុសលនីមួយៗ គេតែងតែតាំងសូត្រនមោ៣ចប់ជាដរាប ដូចគ្នានឹងអំបិលរមែងជាប្រធាននៃសម្ល សឹងជាវត្ថុដែលលះបង់ចោលចេញមិនបានដូច្នោះដែរ ថែមទាំងបុរាណសម័យក៏និយមប្រើសូត្រជាហូរហែមកផង ដូនកាលវេលានឹងឱ្យកូនសិស្សរៀនសូត្រធមិអាចិសាស្ត្រាបាលីឬនឹងធ្វើពិធីអ្វីៗក្តី ក៏លោកតែងឱ្យតាំងនមោ៣ចប់ជាមុន ហាក់ដូចជា “នមោ” នេះ ជាធមិខ្លាំងពូកែស័ក្តិសិទ្ធិ អាចបណ្តុះបណ្តាលនៃការសិក្សាសូត្ររៀននឹងពិធីនោះឆាប់បានសម្រេចផលដូចបំណង ន័យត្រង់នេះគប្បីឃើញបានតាមបែបក្បួនតម្រាចាស់ៗ ច្រើនតាំងឡើងក្នុងពេលដំបូងដែលនឹងរៀនថា “**នមោ ពុទ្ធាយ សិទ្ធំ...**” ដូច្នេះជាដើម សូម្បីព្រះគន្ថរចនាចារ្យទាំងឡាយដែលជាអ្នករចនាបាលីនិងអដ្ឋកថា តាំងផ្តើមនមស្ការជាមុនសិនដែរ ដែលហៅថាបណាមគាថា ដល់សម័យក្រោយយើងជាពុទ្ធមាមកជនទាំងឡាយនាំគ្នាហៅថា បទនមស្ការឬការតាំងនមោដើម្បីក្រាបថ្វាយបង្គំ នមស្ការដល់ព្រះជាម្ចាស់ថ្លៃរួចហើយទើបគោរពឱនលំទោនដល់អ្នកដែលមានគុណ ដូចជាគ្រូឧបជ្ឈាយ៍អាចារ្យជាដើមឬចំពោះជនណាៗ ដែលខ្លួនធ្លាប់រាប់អានថាពូកែស័ក្តិសិទ្ធិធុតឆាប់ ដូចសម័យខាងក្រោយនេះ គេច្រើនហៅថាថ្វាយគ្រូ របៀបនេះជាប្រពៃណីនិយមដែលជាប់តំណតមកអំពីបុព្វបុរសជាន់មុន។

មែនពិត “**នមោ**” នេះ មានមកអំពីទីច្រើនកន្លែង ដូចជា នមោ៨បទ, នមោក្នុងមោរបរិត្តនិងនមោក្នុងអាដានាដិយបរិត្តជាដើម, តែនមោដែលមានមកក្នុងគម្ពីរ

ដទៃៗ នឹងលើកលែងមិនបាច់អធិប្បាយ។ ក្នុងទីនេះនឹងអធិប្បាយចំពោះបទ “នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស” ប៉ុណ្ណោះ ដែលជាប្រធាននៃបទនមស្ការ ដែលយើងធ្លាប់មាត់ធ្លាប់កជាយូរយារមកហើយ យើងនឹងទាញឧទាហរណ៍មកផ្សំជាមួយនឹងសេចក្ដីអធិប្បាយ ដែលមានន័យសង្ខេបៗដូចតទៅនេះ ៖

បទថា “នមោ” នោះ សម័យជាន់ដើមគ្រាន់តែជាពាក្យឧទាន ដែលជនទាំងឡាយនោះៗបន្លឺឡើងដោយសេចក្ដីប្រីតាប្រាមោទ្យរបស់ចិត្ត ដើម្បីប្រកាសសេចក្ដីជ្រះថ្លានិងសេចក្ដីអស្ចារ្យចិត្ត ក្នុងព្រះប្រាជ្ញាញាណនៃព្រះដ៏មានព្រះភាគជាម្ចាស់ឬដែលមានសេចក្ដីជ្រះថ្លាស្រាប់ហើយ គ្រាដល់ជួបប្រទះហេតុអាសន្នអន្ទក្រ ឆាប់ប្រញាប់បន្លឺឡើងនូវឧទានវាចា ដើម្បីការពារសត្រូវនិងសេចក្ដីអន្តរាយផ្សេងៗ តែរឿងរ៉ាវរបស់នមោនេះ មានគោលចារឹកប្រាកដច្បាស់ថា ក្នុងសម័យពុទ្ធកាល ឥតមានពោលចំពោះព្រះភ័ក្ត្រព្រះសាស្ដា ដូចដែលយើងពោលចំពោះព្រះភ័ក្ត្រព្រះបដិមាក្នុងឥឡូវនេះទេ (ដូចវេលាសូត្រមន្ត ថ្វាយបង្គំព្រះក្នុងវិហារ សាលា) ជាពាក្យពោលដោយស្វាត់កំបាំងស្ទើរទាំងអស់ក៏ថាបាន តាមពិតក៏គួរតែនឹងដូច្នោះមែន ព្រោះសម្ដីថា “តស្ស ភគវតោ” ដែលប្រែថា ដល់ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ឥតបំណងថាជាពាក្យពោលចំពោះមុខទេ គឺចង្អុលឱ្យឃើញថាជាពាក្យពោលបិទៗ បាំងៗ ដោយត្រង់។

តទៅនេះនឹងចាប់និយាយអំពីបទថា:

“នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស” ព្រមទាំងនិទានជាឧទាហរណ៍ដូចតទៅនេះ ៖

## ឆាមនៃអ្នកពោល នមោ គ្រាដំបូង

នមោ សាតាគិរិយក្ខោ តស្ស អសុរិន្ទោ បវុច្ចតិ ភគវតោ ចាតុ-មហារាជិកា អរហតោ សក្កោ តថា សម្មាសម្ពុទ្ធស្សាតិ មហាព្រហ្មោហិ បវុច្ចតិ ឥតិ ឯវំ បញ្ច ទេវេហិ បតិដ្ឋិតាតិ។

១–នមោ សាតាគិរិយក្ស ពោលនមស្ការ,

២–តស្ស អសុរិន្ទរាហូ ពោលនមស្ការ,

៣–ភគវតោ ស្ដេចចាតុមហារាជិកា ពោលនមស្ការ,

៤–អរហតោ ស្ដេចសក្កទេវរាជ ពោលនមស្ការ,

៥–សម្មាសម្ពុទ្ធស្ស សោកមហាព្រហ្ម ពោលនមស្ការ។

ទេវតាទាំង៥ព្រះអង្គនេះ ជាអ្នកពោលនមស្ការ មួយអង្គមួយបទៗ រៀងៗខ្លួន ព្រះគាថានេះមានប្រាកដក្នុងដីកាមង្គលមួយរយប្រាំបី (១០៨) ដែលព្រះអរហន្តទាំងឡាយ បានប្រមូលដោយតក្រែងទុក ឱ្យជាបទមួយជាមួយគ្នា សម្រាប់នឹងបាននមស្ការចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំង៣ប្រភេទ។

ន័យមួយទៀត ក្នុងសុត្តន្តបិដក មាននិទានខ្លីៗនិងសេចក្ដីដែលគួរចូលចិត្តបាន ដែលមានមកក្នុងព្រះសូត្រនោះៗដូច្នេះ ៖

១–នមោ ដែលមានមកក្នុងសក្កបញ្ហសូត្រ មានរឿងដំណាលថាៈ កាលនោះសម្ដេចអមរិន្ទ មានទេវបំណងនឹងស្ដេចទៅគាល់ព្រះសាស្ដា ទើបបានទ្រង់តាំងគន្ធព្វទេវបុត្រឱ្យជាមគ្គុទ្ទេសនាំផ្លូវព្រះអង្គ ស្ដេចព្រមដោយទេវបរិវារ មកកាន់សម្នាក់ព្រះបរមសាស្ដា តែក្នុងវេលានោះព្រះអង្គនៅនាសត្តប្បណ្ណគូហា ជិតភ្នំវេទយិកាបពិតក្នុងតំបន់អម្ពសណ្ឌៈ ក្នុងដែនរាជគ្រឹះ ទ្រង់ទូលសន្ទនាការប្រាស្រ័យជាមួយនឹងព្រះសម្ពុទ្ធបរមគ្រូល្មមសមគួរហើយ ទើបទូលសួរបញ្ហាកម្មជ្រៅៗ ព្រះសម្ពុទ្ធជាម្ចាស់

ទ្រង់ឆ្លើយដោះស្រាយដរាបដល់ព្រះអង្គអស់សេចក្តីសង្ស័យ ហើយទ្រង់ប្រកាសនូវសេចក្តីរីករាយសាទរយ៉ាងក្រៃលែង ក្នុងការដែលបានទទួលក្រេបរសធម៌ទេសនាជាដើមថា ព្រះអង្គនឹងបានចម្រើនព្រះជន្មាយុយឺនយូរប្រសិនបើចុតិអំពីទេវលោកក៏គង់មិនបានទៅកាន់អបាយភូមិទៀតតទៅ។ ស្រេចហើយទើបមានទេវបញ្ជានឹងគន្ធព្វទេវបុត្រថា លោកជាអ្នកមានឧបការៈច្រើនដល់យើង ដែលបានញ៉ាំងព្រះសាស្ដាឱ្យទ្រង់ជ្រះថ្លាជាដំបូង ហើយបាននាំយើងចូលទៅកាន់សម្នាក់ព្រះអង្គក្នុងពេលខាងក្រោយ ណ្ហើយចុះ យើងនឹងឱ្យលោកបានតំណែងជាគន្ធព្វទេវរាជ។ ក្នុងទីបំផុត សម្ដេចអមរិន្ទឥន្ទកោសីយ ទ្រង់បានយកព្រះហស្តពាល់ចាប់ផែនដី ហើយបន្លឺព្រះឧទានវាចាដោយសេចក្តីត្រេកអររីករាយក្នុងព្រះទ័យថាៈ “**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**” ដូច្នេះចំនួន៣ដង។

២–**នមោ** ដែលមានមកក្នុងបិយជាតិកសូត្រ មានរឿងពោលទុកថាៈ គហបតីម្នាក់មានកូនប្រុសមួយជាទីស្រឡាញ់ពេញចិត្ត កូននោះទទួលអនិច្ចកម្មទៅ ចំណែកគហបតីជាបិតាមានសេចក្តីយំសោកខ្សឹកខ្សួល អាឡោះអាល័យស្ដាយបុត្រជាពន់ប្រមាណដរាបដល់ឈប់ធ្វើការងារចិញ្ចឹមជីវិត គិតតែដេកសម្ងំនិងយំកន្ទក់កន្ទេញបម្រះនទៀលរៀបរាប់ដោយប្រការផ្សេងៗ ថ្ងៃមួយគាត់បានចូលទៅគាល់ព្រះសាស្ដាៗ ត្រាស់បង្គាប់ឱ្យសួររឿងហេតុរួចហើយ ទើបត្រាស់ថាៈ ម្នាលគហបតី សេចក្តីសោយសោក អាឡោះអាល័យនិងទុក្ខទោមនស្សទាំងឡាយនេះ សុទ្ធតែកើតឡើងអំពីសេចក្តីស្រឡាញ់ មានរបស់ស្រឡាញ់ជាដែនកើតទាំងអស់។ គាត់ក៏មិនត្រេកអរមិនជំទាស់តិះដៀលព្រះពុទ្ធភាសិត គ្រាន់តែក្រោកអំពីទីអង្គុយហើយដើរចៀសចេញទៅ ហើយទៅពោលពណ៌នារឿងនោះប្រាប់ឱ្យអ្នកដទៃស្តាប់។ ដំណឹងព្រះពុទ្ធ

ភាសិតនេះបានឮផ្សាយរហូតទៅដល់ព្រះបរមរាជវាំង។ ព្រះបាទបសេនទិកោសល ទើបត្រាស់សួរព្រះនាងមល្លិកាថាៈ ព្រះសមណគោតម ពោលដូច្នោះមែនឬមល្លិកា? មែនហើយព្រះអង្គ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សេចក្ដីតែម្យ៉ាងប៉ុណ្ណោះ សូមទ្រង់ព្រះមេត្តាប្រោស។

ព្រះរាជាទ្រង់មិនជឿហើយមានព្រះបន្ទូលថាៈ មល្លិកានេះឱ្យតែព្រះសមណ-គោតមពោលថាដូចម៉េចៗ ចេះតែយល់ឃើញថាពិតៗទាំងអស់ ប្រហែលគ្នាសិស្សនិងអាចារ្យ និយាយអ្វីៗក៏និយាយតាមគ្នាទៅ ហើយក៏ទ្រង់បណ្ដេញព្រះនាងឱ្យចេញទៅ។

ថ្ងៃមួយខាងក្រោយ ព្រះនាងចូលទៅគាល់ព្រះរាជា ហើយទូលអធិប្បាយព្រះពុទ្ធភាសិតនោះដោយពិស្ដារ តែក្នុងទីនេះនឹងច្បិចលើកយកចំពោះតែសេចក្ដីសំខាន់មកសម្ដែងឱ្យឃើញថា ព្រះនាងទូលសួរព្រះមហាក្សត្រថាៈ បពិត្រព្រះមហារាជ វជិរីកុមារីរាជធីតារបស់ព្រះអង្គក្ដី, ព្រះនាងវាសភខត្តិយាក្ដី, វិឌូឌភនោបតីក្ដី, ខ្លួនព្រះនាងខ្ញុំជាម្ចាស់ក្ដី, ដែនកាសីនិងកោសលក្ដី ទាំងអម្បាលនេះជារបស់ស្រឡាញ់ពេញព្រះទ័យខ្លះឬទេ? ព្រះរាជាតបថាៈ ចាំបាច់ទៅនិយាយអ្វី មល្លិកា! របស់ទាំងនេះ សូម្បីតែមួយមុខៗនោះ ក៏យើងនៅតែស្រឡាញ់ពេញចិត្តទាំងអស់។ ចុះបើរបស់ទាំងនោះវិនាសព្រាត់ប្រាសឬប្រែប្រួលទៅដោយប្រការផ្សេងៗ ព្រះអង្គនឹងទ្រង់ទោមនស្សខ្លះឬទេ? ណ្ហើយចុះ មល្លិកា សូម្បីតែខ្លួនយើងក៏គង់ដឹងជាក់ថាជាសេចក្ដីទុក្ខយ៉ាងធំ ព្រះនាងចេះតែទទួចទូលថាហ្នឹងហើយ! មហាបពិត្រ សេចក្ដីសមដូចពុទ្ធភាសិតដែលព្រះដ៏មានព្រះភាគត្រាស់មិនមែនទេឬ? ព្រះដ៏មានព្រះភាគជាព្រះអរហន្ត ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ទ្រង់បំណាងយកសេចក្ដីនេះ ទើបទ្រង់

ត្រាស់ថា “សេចក្ដីសោកសង្រេងសង្រែ អាឡោះអាល័យនិងទុក្ខទោមនស្សទាំងឡាយ សុទ្ធតែកើតមានឡើងមកអំពីសេចក្ដីស្រឡាញ់ មានរបស់ស្រឡាញ់ជាដែនកើតមុន” ដូច្នេះ។

មែនហើយ មល្លិកា! គួរអស្ចារ្យណាស់ហ្ន៎! មិនធ្លាប់មានមកពីមុនឡើយ! ប្រាកដជាព្រះដ៏មានព្រះភាគទ្រង់ចាក់ធ្លុះចំពោះ ដោយព្រះប្រាជ្ញាញាណ ទើបបានទ្រង់ឃើញនូវហេតុនេះយ៉ាងជាក់ច្បាស់។ ព្រះរាជាទ្រង់ពេញព្រះទ័យ ដរាបដល់ស្ដេចក្រោកឡើងពីអាសនៈ ទ្រង់ពានាព្រះភូសា តៀងព្រះអង្សាខាងស្ដាំ ហើយទ្រង់បន្លឺឧទានវាចាដោយសេចក្ដីជ្រះថ្លាថាៈ “**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**” ដូច្នេះ៣ដង។

៣–នមោ ដែលមានមកក្នុងព្រហ្មាយុសូត្រនោះ មានរឿងដំណាលទុកថាៈ មានព្រាហ្មណ៍ចាស់ម្នាក់ ជាគណាចារ្យយ៉ាងធំឈ្មោះ ព្រាហ្មាយុ មានអាយុ១២០ឆ្នាំ បានជ្រាបព្រះកិត្តិយសដែលលាន់ឮរន្ទឺល្បីមកថាៈ ព្រះសមណគោតមស្ដេចចេញទ្រង់ព្រះផ្នួសអំពីសក្យត្រកូល ហើយបានត្រាស់ដឹងធម៌ពិសេសទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង ជាព្រះអរហន្តឯកក្នុងលោក គ្មានគូប្រៀបជាដើម ឥឡូវនេះព្រះអង្គទ្រង់សម្ដែងធម៌ប្រោសប្រដៅដល់មហាជន មានព្រះកិត្តិស័ព្ទល្បីល្បាញខ្ចរខ្ចារខ្ចរខ្ចាយឮសាយសុសសព្វសព្វសុធា ព្រាហ្មណ៍មានបំណងប៉ងប្រាថ្នាចង់ជ្រាបនូវសេចក្ដីពិត ដូចមាត់អ្នកដងគេនិយាយនោះមែនឬទេ ទើបហាមាត់ហៅឧត្តរមាណពដែលជាសិស្សសំណព្វចិត្តតែមួយ ឱ្យជួយទៅស៊ើបសាកសួររកសេចក្ដីពិត។ ឧត្តរមាណពទទួលយ៉ាងឆាប់នូវពាក្យបង្គាប់នៃលោកអាចារ្យហើយ បានត្រាច់ដើររង្គាត់សង្វាតរកតាមលំដាប់រហូតចូលទៅដល់ទីដែនវិទេហៈ ដែលព្រះសាស្ដាស្ដេចគង់

នៅ គាត់ក៏ចូលទៅជិតគាល់ព្រះអង្គ ទើបក្រាបទូលសួរសន្ទនាប្រាស្រ័យ លុះល្មមសមគួរហើយទើបលុតជង្គង់អង្គុយចុះ។ គាត់បានគន់គូពិចារណាមើលមហាបុរិសលក្ខណៈ៣២ប្រការ ដែលមានក្នុងព្រះកាយរបស់ព្រះសាស្តា ឃើញគ្រប់សព្វបរិបូណ៌ គាត់ក៏មានសេចក្តីត្រេកអរសោមនស្សយ៉ាងចំហុត តែមានបំណងបួងបាច់ចង់ជ្រាបចង់ដឹងឱ្យក្រៃលែងតទៅទៀត ទើបឃ្លាំចាំមើលជាប់តាមព្រះអង្គគ្រប់ឥរិយាបថដូចស្រមោលទៅតាមខ្លួនអស់រវាះចំនួន៧ខែទើបបានដឹងច្បាស់។ លុះអស់សេចក្តីវិមុត្តសង្ស័យហើយ ទើបគាត់ប្រញាប់ប្រញាល់វិលត្រឡប់មកកាន់ក្រុងមិថិលាវិញ ចូលទៅកាន់សម្នាក់អាចារ្យ និយាយរៀបរាប់អំពីរឿងរ៉ាវផ្សេងៗ តាំងតែអំពីខាងដើមរហូតដល់ចប់ឱ្យព្រាហ្មណ៍ជាអាចារ្យស្តាប់។ ព្រហ្មាយុព្រាហ្មណ៍ចាស់ជរាក៏ពេញត្រៀបទៅដោយប្រីតាប្រាមោទ្យ បន្លឺនូវឧទានវាចាដោយសេចក្តីត្រេកអររីករាយនៃចិត្តថាៈ “នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស” ដូច្នេះ ៣ដង។

៤–នមោ ដែលមានមកក្នុងគារវសូត្រ មាននិទានលោកពោលទុកថាៈ ក្នុងដែនកោសលមាននាងព្រាហ្មណីម្នាក់ឈ្មោះ ធនញ្ជានី ជាស្រីមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះពុទ្ធសាសនា អាស្រ័យនៅក្នុងស្រុកឈ្មោះ អចលកប្បៈ បានជាភរិយានៃភារទ្វាជព្រាហ្មណ៍ ដែលត្រូវជាបងប្រុសអក្កោសកភារទ្វាជព្រាហ្មណ៍ នាងជាព្រះសោតាបន្នបុគ្គល នាងនោះកណ្តាស់ក្តី ក្អកក្តី ភ្លាត់ភ្លាំងរអិលជំពប់ក្តី នាងច្រើនតែភ្ញាក់លាន់មាត់បន្លឺឧទានវាចាថាៈ “នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស” ដូច្នេះជានិច្ចកាល។ រឿងនេះបើចង់ពិស្តារចូរទៅមើលក្នុងព្រាហ្មណវគ្គ និទានអក្កោសកភារទ្វាជព្រាហ្មណ៍ ទី២៧៨នៃធម្មបទខុទ្ទកនិកាយ

ភាគ៨និងគារវសូត្រនោះចុះ។ ចំណែករឿងរ៉ាវផ្សេងៗ ដែលមានក្នុងសូត្រដូចដែលនាំមកពណ៌នានេះ ក៏គ្រាន់តែជាន័យសង្ខេបដែរ ព្រោះមានសេចក្តីដែលនឹងត្រូវនិយាយតទៅទៀតច្រើន ហេតុនេះសូមសង្ខិតន័យតែប៉ុណ្ណេះ។

## ប្រយោជន៍នៃការពោល នមោ

១-ដើម្បីនឹងឱ្យអ្នកប្រាជ្ញទាំងឡាយលោកជ្រាបថា ការប្រព្រឹត្តិយ៉ាងនេះជិតចំពោះវង្សនៃព្រះអរិយជាម្ចាស់។

២-ដើម្បីការពារសព្វវន្តរាយ។

៣-ដើម្បីនឹងជម្រះសន្តានចិត្តឱ្យបរិសុទ្ធ។

៤-ដើម្បីនឹងឱ្យជីវិតិន្ទ្រីយមានខ្លឹមសារ។

**សេចក្តីសង្ខេត:** ដែលថាជិតចំពោះអរិយប្រពៃណីនោះ ព្រោះព្រះសម្មុទ្ធនិងសប្បុរសទាំងឡាយ កាលដែលនឹងសម្តែងធម៌ក្តី ស្តាប់ធម៌ក្តីនិងធ្វើការមង្គលឯណាៗក្តី រមែងពោលនមស្ការព្រះរតនត្រ័យជាមុន ទាល់តែជាប្រពៃណីជាប់មកដរាបដល់ឥឡូវនេះ។ ដែលថាដើម្បីការពារអន្តរាយ ព្រោះកាលបើបុគ្គលរឭកដល់គុណព្រះរតនត្រ័យជាប់មាំហើយ រមែងមិនមានសេចក្តីតក់ស្លុតរន្ធត់ចិត្ត សូម្បីនឹងត្រូវស្លាប់ក្នុងទីណានោះ ក៏គង់អាចនឹងការពារមិនឱ្យទៅកើតក្នុងចតុរាបាយបាន។ ដែលថាដើម្បីជម្រះសន្តានចិត្តឱ្យបរិសុទ្ធនោះ ព្រោះថាកាលបើបុគ្គលរឭកដល់គុណព្រះរតនត្រ័យហើយ អាចឱ្យកើតបីតិបាមោជ្ជៈក្នុងកាលណា ចំណែកសន្តានចិត្តរមែងបរិសុទ្ធប្រាសចាករាគៈ ទោសៈ មោហៈ ក្នុងកាលណោះ។ ដែលថាគប្បីឱ្យជីវិតមានខ្លឹមសារនោះ ព្រោះអ្នកដែលមានប្រាជ្ញាពិចារណាឱ្យឃើញគុណព្រះរតនត្រ័យជាក់ច្បាស់ហើយ ឈ្មោះថាជាអ្នកបានបំពេញធ្វើជីវិតរបស់ខ្លួនឱ្យមានខ្លឹម

សារដោយពិតប្រាកដ។

## ហេតុដែលត្រូវពោលនមោ៣ចប់

១-ដើម្បីនឹងធ្វើការតាំងនមស្ការនោះឱ្យខ្ជាប់ខ្ជួនមាំមួន។

២-ដើម្បីនឹងនមស្ការដល់ព្រះពុទ្ធទាំង៣ប្រភេទ។

## នមោ៣ចប់សម្រាប់នមស្ការដល់ព្រះពុទ្ធទាំង៣ប្រភេទ

ចប់ទី១-សម្រាប់នមស្ការព្រះសម្ពុទ្ធជាសទ្ធាធិក

ចប់ទី២-សម្រាប់នមស្ការព្រះសម្ពុទ្ធជាបញ្ញាធិក

ចប់ទី៣-សម្រាប់នមស្ការព្រះសម្ពុទ្ធជាវីរិយាធិក

គោលចំណាំ: ដំណើសេចក្តីទាំងអស់នេះ បានដកពីគម្ពីរសុមង្គលវិលាសិនីដីកា១, ខុទ្ទកបាឋ១, បរមត្ថជោតិកា១, និទានសំយុត្ត១។

## ព្រះត្រៃសរណាគមន៍

ព្រះពុទ្ធ–ព្រះធម៌–ព្រះសង្ឃ ត្រូវជា៣។

## កន្លែងដែលត្រាស់ត្រៃសរណាគមន៍

ព្រះត្រៃសរណគមន៍នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់នាព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ដល់ព្រះអរហន្តសាវ័កទាំង៦០អង្គ ដែលទ្រង់នឹងបញ្ជូនទៅប្រកាសព្រះពុទ្ធសាសនា ដោយមានពុទ្ធបំណងនឹងឱ្យសម្រេចកិច្ចបព្វជ្ជានិងឧបសម្បទាដល់កុលបុត្រទាំងពួង ដោយពិធីកាន់យកព្រះត្រៃសរណគមន៍នេះហៅថា តិសរណគមនូបសម្បទា។

(តពីសារត្ថសង្គហៈ ប្រែចេញពីសៀម)

## វត្ថុបំណាច់នៃព្រះរតនត្រ័យ

១-រមិតព្វំ រម្មន្តិ ឯត្ថាតិ រំ។

ជនទាំងឡាយតែងត្រេកអរនូវវត្ថុដែលអរិយបណ្ឌិត គប្បីត្រេកអរក្នុងប្រជុំ៣នៃបូជនីយវត្ថុនេះ ហេតុនោះ ប្រជុំ៣នៃបូជនីយវត្ថុ (គឺរតនត្រ័យ) នេះ ទើបបាននាមថា រ:។

២-អត្តានំ ភជន្តេ ឧបសេវន្តេ ទុគ្គតិតោ សំសារមហាណ្ណវតោ វា តារេតីតិ តំ។

ប្រជុំ៣នៃបូជនីយវត្ថុឯណា តែងញុំាងជនអ្នកគប់ គឺថាចូលទៅសេពនូវខ្លួនឱ្យឆ្លងផុតពីទុគ្គតិនិងអន្លង់មហាណ្ណព គឺសង្សារវដ្ត ហេតុនោះប្រជុំ៣នៃបូជនីយវត្ថុនោះ ទើបបាននាមថា ត:។

៣-អត្តានំ អនុស្សរន្តេ សុគតិ និព្វានានិ នេតីតិ នំ។

ប្រជុំ៣នៃបូជនីយវត្ថុឯណា តែងនាំជនអ្នករឭកដល់ខ្លួនទៅកាន់សុគតិនិងព្រះនិព្វាន ហេតុនោះ ប្រជុំ៣នៃបូជនីយវត្ថុនោះ ទើបបាននាមថា ន:។

(ដកពីអភិធានប្បទីបិកា សូចិ)

សេចក្តីសង្ខេប: រតនៈនេះគេចែកចេញជា៣អក្សរ គឺត្ួមកពី រមៈ ធាតុ ក្នុងអត្ថថា ត្រេកអរ។ តៈ មកពី តរៈ ធាតុ ក្នុងអត្ថថា ឆ្លង។ នៈ មកអំពី និ ធាតុ ក្នុងអត្ថថា ឱ្យដល់។ រួមចូលគ្នាជា រតនៈ ប្រែថា ជាទីត្រេកអរ (រីករាយ) របស់អ្នកប្រាជ្ញ១។ ជាគ្រឿងឆ្លងផុតពីទុគ្គតិនិងសង្សារវដ្ត១។ ជាគ្រឿងនាំឱ្យដល់សុគតិនិងព្រះនិព្វាន១។

### សរណាគមន៍មាន២យ៉ាងគឺ:

១-លោកិយសរណាគមន៍ បានដល់សរណាគមន៍របស់បុថុជ្ជន។

២-លោកុត្តរសរណាគមន៍ បានដល់សរណាគមន៍របស់ព្រះអរិយ។

(ដកពីអដ្ឋកថា សាមញ្ញផលសូត្រ ទីឃនិកាយ)

សេចក្តីសង្ខេបៈ សរណគមន៍ ដែលមិនខ្ជាប់ខ្ជួនអាចដាច់ធ្លុះធ្លាយ ឈ្មោះថា លោកិយសរណគមន៍។ សរណគមន៍ ដែលមាំទាំស្ថិតស្ថេរ មិនចេះធ្លុះធ្លាយ ឈ្មោះថា លោកុត្តរសរណគមន៍។

## ហេតុនាំឱ្យដាច់លោកិយសរណគមន៍២យ៉ាងគឺៈ

១-ព្រោះកាន់លទ្ធិដទៃក្រៅពុទ្ធសាសនា។

២-ព្រោះទម្លាយខន្ធរលត់នូវជីវិតិន្ទ្រិយ។

សេចក្តីសង្ខេបៈ បុគ្គលដែលដល់ព្រះរតនត្រ័យថាជាទីពឹងទីរឭកហើយ ពេលខាងក្រោយចូលទៅរាប់អានសាសនាដទៃ យល់ឃើញថា បុគ្គលនិងវត្ថុដទៃថាល្អជាងព្រះរតនត្រ័យ សរណគមន៍ក៏ដាច់ លុះធ្វើកាលកិរិយាទម្លាយខន្ធស្លាប់ទៅ ក៏ជាហេតុឱ្យត្រៃសរណគមន៍ដាច់ដូចគ្នាដែរ។

## ផលនៃការដាច់ត្រៃសរណគមន៍២យ៉ាងគឺៈ

១-សាវជ្ជោ ដាច់ប្រកបដោយទោស។

២-អនាវជ្ជោ ដាច់ដោយមិនមានទោស។

សេចក្តីសង្ខេបៈ ដាច់ប្រកបដោយទោស សម្តៅយកការដាច់សរណគមន៍ព្រោះកាន់លទ្ធិសាសនាដទៃ។ ដាច់មិនមានទោស សម្តៅយកការដាច់សរណគមន៍ព្រោះធ្វើកាលកិរិយាទម្លាយខន្ធ។

## ហេតុដែលនាំឱ្យសៅហ្មងត្រៃសរណគមន៍៣យ៉ាងគឺៈ

១-អវិជ្ជា មិនដឹងលក្ខណៈនៃព្រះរតនត្រ័យ។

២-វិចិកិច្ឆា សន្ទិះសង្ស័យក្នុងគុណព្រះរតនត្រ័យ។

៣-មិច្ឆាទិដ្ឋិ មានសេចក្ដីយល់ឃើញខុស។

សេចក្ដីសង្ខេប: បុគ្គលដែលប្រាសចាកបញ្ញា មិនដឹងច្បាស់ថា ព្រះរតនត្រ័យនោះមានលក្ខណៈដូចម្ដេច ល្អវិសេសយ៉ាងណាក្ដី មានសេចក្ដីសន្ទិះសង្ស័យថា ព្រះរតនត្រ័យនឹងជាសរណៈដ៏ប្រសើរមែនឬមិនមែនក្ដី មានសេចក្ដីយល់ឃើញខុសពីព្រះរតនត្រ័យក្ដី សឹងសុទ្ធតែជាហេតុបណ្ដាលឱ្យត្រៃសរណគមន៍របស់ខ្លួនសៅហ្មង មិនដូរជង់រុងរឿងបរិសុទ្ធបានឡើយ។

**ហេតុដែលធ្វើឱ្យត្រៃសរណគមន៍រុងរឿងនៃត្រៃសរណគមន៍៣យ៉ាងគឺ:**

១-មានបញ្ញាដឹងស្គាល់ច្បាស់ក្នុងគុណព្រះរតនត្រ័យ។

២-ប្រាសចាកសេចក្ដីសន្ទិះសង្ស័យ។

៣-សម្មាទិដ្ឋិ ឃើញត្រូវប្រពៃក្នុងព្រះរតនត្រ័យ។

**លោកិយសរណគមន៍៤យ៉ាងគឺ:**

១-អត្តសន្និយាតសរណគមនំ ដល់ព្រះរតនត្រ័យ ដោយប្រគល់កាយថ្វាយជីវិត។

២-តប្បរាយនតាសរណគមនំ ដល់ព្រះរតនត្រ័យ ដោយលើកគុណព្រះរតនត្រ័យទុកក្នុងខាងដើម។

៣-សិស្សភាវូបគមនសរណគមនំ ដល់ព្រះរតនត្រ័យ ដោយថ្វាយខ្លួនទុកជាសិស្ស។

៤-បណិបាតសរណគមនំ ដល់ព្រះរតនត្រ័យ ដោយគោរពសំពះថ្វាយបង្គំ។

(ដកពីអដ្ឋកថា សាមញ្ញផលសូត្រ ទីឃនិកាយ)

សេចក្ដីសង្ខេប: អត្តសន្និយាតសរណគមន៍នោះ ដូចបញ្ចេញវាចាថា "អជ្ជ អាទិ កត្វា អហំ អត្តានំ ពុទ្ធស្ស និយាទេម។ល។ ធម្មស្ស និយា-ទេម។ល។ សង្ឃស្ស និយាទេម" ខ្ញុំម្ចាស់ធ្វើថ្ងៃនេះឱ្យជាដើម ហើយសូមប្រគល់កាយថ្វាយជីវិតដល់ព្រះពុទ្ធជាម្ចាស់។ល។ ដល់ព្រះធម៌។ល។ ដល់ព្រះសង្ឃជាម្ចាស់។ តប្បរាយនតាសរណគមន៍ បញ្ចេញវាចាថា "អជ្ជ អាទិ កត្វា អហំ ពុទ្ធ-ប្បរាយនោ ឥតិមំ ធារេថ។ល។ ធម្មប្បរាយនោ។ល។ សង្ឃប្បរាយនោ ឥតិមំ ធារេថ" ចាប់ដើមអំពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយចូរចាំខ្ញុំម្ចាស់ទុកថា មានព្រះពុទ្ធជាម្ចាស់ជាខាងមុខ។ល។ មានព្រះធម៌។ល។ មានព្រះសង្ឃជាម្ចាស់ជាខាងមុខ។ សិស្សភាវូបគមនសរណគមន៍ បញ្ចេញវាចាថា "អជ្ជ អាទិ អហំ ពុទ្ធស្ស អន្តេវាសិកោ ធម្មស្ស សង្ឃស្ស ឥតិមំ ធារេថ" ចាប់ដើមអំពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយ ចូរចាំខ្ញុំម្ចាស់ទុកថាជាអន្តេវាសិករបស់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ បាណិបាតសរណគមន៍ បញ្ចេញវាចាថា "អជ្ជ អាទិ កត្វា អភិវាទនបច្ចុប្បដ្ឋានំ អញ្ជលិកម្មំ ពុទ្ធាទីនំ យេវ តិណ្ណំ វត្ថូនំ ករោមិ ឥតិ ធារេថ" ចាប់ដើមតាំងពីថ្ងៃនេះជាដើមទៅ សូមលោកទាំងឡាយចូរចាំខ្ញុំម្ចាស់ទុកថា ខ្ញុំម្ចាស់នឹងធ្វើអភិវាទនកិច្ចនិងក្រោកឡើងទទួលនិងធ្វើអញ្ជលិកម្មនិងសាមីចិកម្ម ដល់វត្ថុទាំងឡាយ៣ មានព្រះពុទ្ធជាម្ចាស់ជាដើម។

## ហេតុនៃការថ្វាយបង្គំមាន៤យ៉ាងគឺ:

១-ញាតិបាណិបាត ថ្វាយបង្គំគោរព ដោយប្រកាន់ថាត្រូវជាញាតិ។

២-ភយបាណិបាត ថ្វាយបង្គំគោរព ព្រោះខ្លាចក្រែង។

៣-អាចរិយបាណិបាត ថ្វាយបង្គំគោរព ដោយប្រកាន់ថាត្រូវជាអាចារ្យ។

៤-ទក្ខិណេយ្យបាណិបាត ថ្វាយបង្គំគោរព ដោយសម្គាល់ថាជាទក្ខិណេយ្យបុគ្គល។

(ដកពីអដ្ឋកថា សាមញ្ញផលសូត្រ ទីឃនិកាយ)

សេចក្តីសង្ខេប: បុគ្គលដែលថ្វាយបង្គំគោរពព្រះសាស្តា ដោយការសម្គាល់ថា ព្រះពុទ្ធអង្គត្រូវជាបរមញាតិ ឈ្មោះថា ញាតិបាណិបាត។ បុគ្គលដែលមានសេចក្តីខ្លាចក្រែងចំពោះព្រះពុទ្ធជាម្ចាស់ថា ព្រះអង្គជាបុគ្គលមានឥទ្ធានុភាព បើមិនថ្វាយបង្គំទៅ ខ្លាចក្រែងព្រះអង្គនឹងប្រទូសរ៉ាយដល់ខ្លួន ហើយក៏ថ្វាយបង្គំគោរពទៅ ឈ្មោះថា ភយបាណិបាត។ បុគ្គលដែលថ្វាយបង្គំព្រះសាស្តាដោយរាប់អានថា ព្រះអង្គធ្លាប់ជាគ្រូ ជាអាចារ្យ ឈ្មោះថា អាចរិយបាណិបាត។ បុគ្គលដែលថ្វាយបង្គំគោរពឱនលំទោនព្រះសម្ពុទ្ធបរមគ្រូ ដោយសម្គាល់ថា ព្រះអង្គជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ឈ្មោះថា ទក្ខិណេយ្យបាណិបាត។ ការក្រាបថ្វាយបង្គំគោរពទាំង៣ខាងដើមមិនរាប់ថាជាសរណគមន៍ទេ ដែលរាប់ថាជាសរណគមន៍បានចំពោះតែទក្ខិណេយ្យបាណិបាតប៉ុណ្ណោះ។

## គុណានុភាពនៃរតនត្រ័យ៥យ៉ាងគឺ:

“ចិត្តីកតំ មហគ្ឃញ្ច អតុលំ ទុល្លភទស្សនំ អនោមសត្តបរិភោគំ រតនំ តេន វុច្ចតិ”។

១-ចិត្តីកតំ ជាបូជនីយវត្ថុ ដែលបុគ្គលទូលទុកក្នុងចិត្ត។

២-មហគ្ឃំ ជាវត្ថុមានថ្លៃច្រើន។

៣-អតុលំ ទ្រទ្រង់នូវគុណ គឺរកបុគ្គលដទៃថ្លឹងស្មើគ្មាន។

៤-ទុល្លភទស្សនំ តិចគ្នាណាស់នឹងបានឃើញ។

៥-អនោមសត្តបរិភោគំ មនុស្សជាន់ទាបរកមិនបាន។

“រតនំ តេន វុច្ចតិ” ហេតុនោះ អ្នកប្រាជ្ញទើបតាំងឈ្មោះថា “រតនៈ”។

(ដកពី និរុត្តិសារមញ្ជូសា ក្នុងបាលីនិយណ្ឌ)

## អានិសង្សលោកុត្តរសរណគមន៍៤យ៉ាងគឺ:

១-រមែងជាបច្ច័យឱ្យសម្រេច សោតាបត្តិផល។

២-រមែងជាបច្ច័យឱ្យសម្រេច សកទាគាមិផល។

៣-រមែងជាបច្ច័យឱ្យសម្រេច អនាគាមិផល។

៤-រមែងជាបច្ច័យឱ្យសម្រេច អរហត្តផល។

## អានិសង្សលោកិយសរណគមន៍

“យេកេចិ ពុទ្ធំ សរណំ គតាសេ ន តេ គមិស្សន្តិ អបាយភូមំ បហាយ មានុសំ ទេហំ ទេវកាយំ បរិបូរេស្សន្តិ” សត្វទាំងឡាយឯណានីមួយដល់នូវព្រះពុទ្ធជាម្ចាស់ថាជាទីពឹងជាទីរឭក សត្វទាំងឡាយនោះនឹងមិនបានទៅកាន់អបាយភូមិឡើយ លះចោលនូវអត្តភាពជាមនុស្សចេញហើយ នឹងបានទៅកើតក្នុងរតនវិមាន ញ៉ាំងពួកអមរទេវតាក្នុងសួគ៌ាល័យឱ្យបរិបូណ៌។

(ដកពី ដីកាមហាសម័យសូត្រ)

## អានិសង្សនៃលោកិយសរណគមន៍ មួយន័យទៀត

“សាធុខោ ទេវានមិន្ទ ពុទ្ធសរណគមនំ ហោតិ” បពិត្រស្តេចសក្កទេវរាជ ព្រះអង្គជាកំពូលនៃទេវតា ជនឯណាបានដល់ព្រះពុទ្ធជាម្ចាស់ថាជាទីពឹងទីរឭក “ពុទ្ធសរណគមនហេតុ ខោ ទេវានមិន្ទ ឯវមិធេកច្ចេ សត្តា កាយស្ស, ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ” បពិត្រសក្កទេវរាជ ព្រះអង្គ

ជាកំពូលនៃទេវតា សត្វទាំងឡាយក្នុងលោកនេះ ចំពោះបណ្ដាជនដែលមានចិត្តបសាទសោមនស្សរាប់អានព្រះពុទ្ធជាម្ចាស់ថាជាទីពឹងទីរឭក លុះកាលទម្លាយបញ្ច-ក្ខន្ធរលត់ផុតអស់ជីវិតិន្ទ្រីយស្រេចហើយ ខាងមុខចុតិចិត្តនោះ នឹងបានទៅបង្កើតក្នុងសុគតិលោកសួគ៌និងបរិបូណ៌ដោយស័ក្ដានុភាព អាចកន្លងលើសនូវទេពតាដទៃដោយហេតុ១០ប្រការគឺៈ

១-ទិព្វេន អាយុនា ដោយអាយុទិព្វវែងជាងទេវតាដទៃ។

២-ទិព្វេន វណ្ណេន ទិព្វរស្មីមានកាយភ្លឺស្វាងជាងទេវតាដទៃ។

៣-សុខេន ដោយសេចក្ដីសុខសាន្តក្នុងឥរិយាបថ៤ច្រើនជាងទេវតាដទៃ។

៤-អធិបតេយ្យេន ដោយសភាវៈជាធំក្រៃលែងជាងទេវតាដទៃ។

៥-យសេន ដោយមានយសច្រើនជាងទេវតាដទៃ។

៦-ទិព្វេហិ រូបេហិ ដោយទិព្វរូបលើសលែងជាងទេវតាដទៃ។

៧-សទ្ទេន ដោយនឹងបានស្ដូរសំឡេងពីរោះអស្ចារ្យជាងទេវតាដទៃ។

៨-គន្ធេហិ ដោយនឹងបានក្លិនក្រអូបបក់ផ្សាយទៅឆ្ងាយជាងទេវតាដទៃ។

៩-រសេហិ ដោយនឹងបានរសដ៏បញ្ចង់វិសេសជាងទេវតាដទៃ។

១០-ផោដ្ឋព្វេហិ ដោយនឹងបានសម្ផស្សដ៏ជាទីចម្រើនចិត្តយ៉ាងក្រៃលែងជាងទេវតាដទៃ។

(ដកពី សារត្ថសង្គហៈប្រែ)

**“កើតឈ្មោះមិនលះបង់ អ្នកតាំងអង្គនៅក្នុងធម៌”**

**អវសានំ**

ស្រាវជ្រាវដោយៈ ជាច់ សុតឹម